ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# សេចក្តីជូនដំណឹង
## ស្តីពី
## ការបើកប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារជូនដល់ បងប្អូនអតីតកម្មករនិយោជិត នៃក្រុមហ៊ុន អេច ស៊ី ស៊ី គ្រុប សាខាខេត្តសៀមរាប

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់បងប្អូនអតីតកម្មករនិយោជិតទាំង **១១២នាក់** (ដូចមានឈ្មោះក្នុងបញ្ជីជូនភ្ជាប់) នៃក្រុមហ៊ុន **អេច ស៊ី ស៊ី គ្រុប (HCC Group Co., Ltd)** សាខាខេត្តសៀមរាប មានទីតាំងស្ថិតនៅភូមិទ្រាំង សង្កាត់ស្លក្រាម ក្រុង-ខេត្តសៀមរាប ជ្រាបថា វិវាទការងាររបស់បងប្អូនជាមួយក្រុមហ៊ុន ត្រូវបានក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ផ្សះផ្សាសះជា ដោយភាគីក្រុមហ៊ុនបានយល់ព្រមផ្តល់ជូនបងប្អូនកម្មករនិយោជិតនូវទឹកប្រាក់សរុបចំនួន **៨១ ៨២៣.២៦ ដុល្លារអាមេរិក** (ប្រាំបីម៉ឺនមួយពាន់ ប្រាំបីរយម្ភៃបីដុល្លារអាមេរិក និងម្ភៃប្រាំមួយសេន) ជាការទូទាត់សម្រាប់អត្ថប្រយោជន៍ដូចខាងក្រោម៖

១. ប្រាក់ឈ្នួលក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារ ២ខែ

២. ប្រាក់ជួសការឈប់សម្រាកប្រចាំដែលនៅសល់ក្នុងឆ្នាំ២០១៩ និងឆ្នាំ២០២០

៣. ប្រាក់ជួសការជូនដំណឹងមុន

៤. ប្រាក់បំណាច់អតីតភាពការងារឆ្នាំ២០១៩ និងឆ្នាំ២០២០

៥. ប្រាក់រំលឹកប្រាក់បំណាច់អតីតភាពការងារមុនឆ្នាំ២០១៩។

សូមបងប្អូនអញ្ជើញទៅបើកប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារនេះដោយខ្លួនឯង ពីក្រុមហ៊ុនដោយផ្ទាល់ **នៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តសៀមរាប នាថ្ងៃទី២២-២៣ ខែមីនា ឆ្នាំ២០២៥ ចាប់ពីម៉ោង ៨:០០នាទីព្រឹក ដល់ម៉ោង ៥:០០នាទីល្ងាច** ដោយភ្ជាប់មកជាមួយនូវឯកសារណាមួយ ដូចខាងក្រោម៖

១. បណ្ណ (កាត) សម្គាល់ខ្លួនកម្មករនិយោជិត (ច្បាប់ដើម) ឬកិច្ចសន្យាការងារ និងសៀវភៅការងារកម្មករនិយោជិត ឬបណ្ណសមាជិក ប.ស.ស. ឬអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន

២. បណ្ណបើកប្រាក់ឈ្នួលប្រចាំខែរបស់កម្មករនិយោជិតម្នាក់ៗ (បើមាន)។

ក្នុងករណីសាមីខ្លួនទទួលមរណភាព សហព័ទ្ធ (ប្តី ឬប្រពន្ធ) អាចទៅបើកប្រាក់នេះជំនួសបាន ដោយភ្ជាប់មកជាមួយនូវឯកសារណាមួយខាងលើ លិខិតបញ្ជាក់មរណភាព និងសំបុត្រអាពាហ៍ពិពាហ៍។

ទន្ទឹមនឹងនេះ ក្រសួងក៏សូមអំពាវនាវដល់បងប្អូនអតីតកម្មករនិយោជិតដែលមិនទាន់ទទួលបានការងារថ្មីធ្វើ សូមមកទទួលយកឱកាសការងារថ្មីពីមជ្ឈមណ្ឌលការងារខេត្តសៀមរាប ដែលប្រចាំការនៅវិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនសៀមរាប ស្ថិតនៅក្នុងសង្កាត់ស្លក្រាម ក្រុង-ខេត្តសៀមរាប ឬទំនាក់ទំនងតាមរយៈទូរសព្ទលេខ ០៦៣ ២១០ ២៧៧/ ០១៦ ៥៣៦ ៦៥៥។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមបងប្អូនជ្រាបជាព័ត៌មាន និងអញ្ជើញទៅបើកប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងាររបស់ខ្លួនតាមកាលកំណត់កុំបីខាន។ ផុតពីរយៈពេលនេះ បងប្អូននឹងត្រូវបានចាត់ទុកថាបានបោះបង់អត្ថប្រយោជន៍នេះចោលដោយខ្លួនឯង។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង លោក ផេង សុភាត (០១២ ៩៨៨ ៤១៨), លោក អ៊ឹម ចំរើន (០១២ ៩៧៦ ១៤៩), លោក ហ៊ុន ចំរើន (០៩២ ៨៦៥ ៥១២)។

ថ្ងៃចន្ទ ១២កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៥

មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តសៀមរាប